# ពលរដ្ឋនៅខេត្តកណ្ដាលបិទផ្លូវមិនឱ្យឡានក្រុមហ៊ុនព្រលានយន្តហោះឆ្លងកាត់បន្ទាប់ពីបើកបរធ្វើឱ្យដីហុយប៉ះពាល់សុខភាព




ពលរដ្ឋជាច្រើនគ្រួសារនៅ ឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាលបានផ្ទុះការតវ៉ានិងដាក់ប៉ារ៉ាស់បិទផ្លូវនៅថ្ងៃអង្គារនេះ ដើម្បីកុំឱ្យរថយន្តរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ព្រលានយន្តហោះបើកឆ្លងកាត់ក្រោយពីបើកបរធ្វើឱ្យដីហុយប៉ះពាល់ដល់ការរស់នៅរបស់ពួកគាត់។

លោក ប៉ាង សំបូរ នៅភូមិតាឡុង ឃុំបឹងខ្យាង បានដាក់ប៉ារ៉ាស់បិទផ្លូវមុខផ្ទះមិនឱ្យរថយន្តបើកឆ្លងកាត់នោះនៅថ្ងៃពុធនេះ។ លោកថា មូលហេតុដែលលោកបិទផ្លូវភ្លាមៗ ដោយសារក្រុមឡានដឹកដី និងថ្មចូលព្រលានមិនបានស្រោចទឹកលើដងផ្លូវ ហើយបណ្ដាលឱ្យដីហុយជាខ្លាំងធ្វើឱ្យប៉ះពាល់ដល់ការរស់នៅរបស់គ្រួសារលោក និងពលរដ្ឋក្នុងភូមិជាពិសេសបញ្ហាសុខភាព។

ពលរដ្ឋរូបនេះបន្តថា ពេលខ្លះដីហុយធ្វើឱ្យហូបបាយមិនកើត និងខោអាវក៏មិនអាចហាលបានដែរ ដោយសារតែផ្លូវជាប់ផ្ទះរបស់គាត់ហុយខ្លាំងពេក។ លោកថា រាល់ថ្ងៃមានឡានដឹកដី និងដឹកថ្មរាប់រយគ្រឿងបានបើកឆ្លងកាត់ផ្លូវមុខផ្ទះរបស់លោកក្នុង១ថ្ងៃៗចូលទៅក្នុងព្រលានយន្តហោះដែលកំពុងសាងសង់ ដោយពួកគេមិនស្រោចទឹកនោះទេ។ លោក ប៉ាង សំបូរ ព្រមានថា  បើសិនជាខាងក្រុមហ៊ុនមិនចេញដោះស្រាយជាមួយពលរដ្ឋទេ លោកនឹងប្រមូលប្រជាពលរដ្ឋក្នុងភូមិទាំងអស់ឡើងទៅតវ៉ានៅមុខសាលាឃុំបឹងខ្យាងដើម្បីទាមទារឱ្យមានដំណោះស្រាយ។

លោកថ្លែងថា៖«**រឿងដឹកចូលព្រលានខ្ញុំមិនឃាត់ទេ ប៉ុន្តែត្រូវស្រោចទឹកផង។ ឡានមិនមែនអាតូចៗណា គឺសុទ្ធតែអាធំៗ។ទាំងខ្ញុំ និងអ្នកផ្សេងទៀត គឺហុយណាស់ មួយថ្ងៃៗ គឺហូបបាយមិនកើតទេ។ បើហុយម្លឹងៗអាណាហូបកើត ក្នុងចានបាយសុទ្ធតែដី**»។

ពលរដ្ឋម្នាក់ទៀតលោក ចិន ធូក បានរៀបរាប់ថា បញ្ហាដីហុយនេះគឺអ្នកភូមិបានរង់ចាំការដោះស្រាយពីអាជ្ញាធរ និងក្រុមហ៊ុនជាច្រើនដងមកហើយ ប៉ុន្តែការរង់ចាំរបស់ពួកគាត់ហាក់គ្មានការឆ្លើយតបពីពួកគេឡើយ។ លោកថា ការបិទផ្លូវនេះគឺគ្រាន់តែចង់ព្រមានដល់ក្រុមហ៊ុនព្រលានយន្តហោះថ្មីធ្វើកិច្ចសន្យាជាមួយពលរដ្ឋ ដើម្បីឱ្យស្រោចទឹកកុំឱ្យប៉ះពាល់ដល់សុខភាពពលរដ្ឋដែលរស់នៅក្នុងភូមិតែប៉ុណ្ណោះ។ លោកថ្លែងថា៖«**មិនដឹងគេគិតមិចទេ បើដីហុយម្លឹងៗ។ គេធ្វើមើលដូចគ្មានមនុស្សរស់នៅ។ ផ្ទះសុទ្ធតែដី ហូបបាយមិនកើតផង។ ខ្ញុំចង់ឱ្យក្រុមហ៊ុនដោះស្រាយជាបន្ទាន់ និងធ្វើកិច្ចសន្យាជាមួយពលរដ្ឋ បើមិនចឹងទេពិបាករស់នៅណាស់ ព្រោះហុយពេក**»។

ក្នុងអំឡុងពលរដ្ឋអ្នកសារព័ត៌មានចុះទៅពិនិត្យសកម្មភាពពលរដ្ឋបិទផ្លូវនោះ គឺមានឡានដឹកដី និងដឹកថ្មជាច្រើនគ្រឿងបានកក់ស្ទះ ប៉ុន្តែមិនឃើញខាងតំណាងក្រុមហ៊ុនព្រលានណាម្នាក់បានចុះដោះស្រាយជាមួយពលរដ្ឋនោះទេ ហើយពលរដ្ឋព្រមានថា បើសិនខាងក្រុមហ៊ុនមិនចេញមុខដោះស្រាយទេ គឺពួកគាត់នៅតែបន្តបិទផ្លូវរហូតមានដោះស្រាយ។

អ្នកបើកបររថដឹកដីម្នាក់បានប្រាប់ឱ្យពលរដ្ឋអ្នកសារព័ត៌មានក្នុងលក្ខខណ្ឌសុំមិនបញ្ចេញឈ្មោះថ្លែងថា លោកមិនដឹងរឿងបញ្ហាស្រោចទឹកទេ។ លោកដឹងត្រឹមតែដឹកដីចូលព្រលានយន្តហោះដែលកំពុងសាងសង់ប៉ុណ្ណោះ។

អ្នកបើកបរឡានថ្លែងថា៖«**ខាងខ្ញុំដឹងតែដឹកទេបង! រឿងស្រោចនេះ គឺខ្ញុំអត់ដឹងទេ។ មិនមែនមានតែក្រុមខ្ញុំមួយទេ។ មានច្រើនក្រុមណាស់បានជាមានឡានច្រើនចឹង។ ទាំងខ្ញុំទាំងគេបង បើហុយម្ល៉ឹងៗ គឺពិបាករស់នៅដូចគ្នា។ ខ្ញុំយល់តើបង តែធ្វើមិចបើខ្ញុំនៅក្រោមគេដែរ**»។

មេឃុំបឹងខ្យាងលោក ណៃ ចាន់ឌី បានថ្លែងថា បញ្ហាផ្លូវនេះ គឺពលរដ្ឋតែងតែរាយការណ៍មកកាន់លោក ដើម្បីឱ្យជួយនិយាយជាមួយក្រុមហ៊ុន ហើយលោកក៏បានប្រាប់បញ្ហានេះដល់ក្រុមហ៊ុនដែរ ដើម្បីជួយគិតគូរដល់ពលរដ្ឋ ប៉ុន្តែពុំមានការឆ្លើយពីខាងក្រុមហ៊ុនឡើយ។

មេឃុំរូបនេះបានទទួលស្គាល់ថា បញ្ហាដីហុយនេះ វាបានប៉ះពាល់ការរស់នៅរបស់ប្រជាពលរដ្ឋ។ លោកថា បញ្ហាពលរដ្ឋតវ៉ានេះលោកនឹងរាយការណ៍ទៅថ្នាក់លើបន្តទៀតដើម្បីស្វែងរកដំណោះស្រាយជូនពលរដ្ឋ។

លោកថ្លែងថា៖«**ហ្នឹងហើយរឿងហុយវាជៀសមិនផុតទេ។ កាលណាមានឡានច្រើនដឹកចឹងនោះ ប៉ុន្តែបើមិនស្រោចទឹកសោះក៏មិនកើតដែរ។ ពូរាយការណ៍អារឿងស្រោចទឹកទៅក្រុមហ៊ុនតែរហូត ព្រោះពេលជិះកាត់ផ្លូវហ្នឹងឃើញថា ហុយខ្លាំងណាស់។ ជាពិសេសរឿងប៉ះពាល់សុខភាពហ្នឹងហ្មង**»។

ជុំវិញរឿងនេះ ពលរដ្ឋអ្នកសារព័ត៌មានមិនអាចសុំការបំភ្លឺពីលោក ជីវ កុកសាយ ជាតំណាងក្រុមហ៊ុនព្រលានយន្តហោះ  អន្តរជាតិតេជោបានទេ។

មន្ត្រីសម្របសម្រួល និងធុរៈកិច្ចនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក វណ្ណ សូផាត មានប្រសាសន៍ថា ករណីពលរដ្ឋតវ៉ាបិទផ្លូវ ដោយសារបញ្ហាដីហុយនេះ គឺជារឿងត្រឹមត្រូវ។ លោកថា អាជ្ញាធរមូលដ្ឋានមានកាតព្វកិច្ចក្នុងការពិនិត្យលើបញ្ហានេះ។

លោក វណ្ណ សូផាត បន្តថា ក្រុមហ៊ុន គឺជាអ្នកទទួលខុសត្រូវទៅតាមកិច្ចសន្យាមុនមានការអភិវឌ្ឍ ថាតើរាល់សកម្មភាពដែលធ្វើ គឺមិនប៉ះពាល់ដល់ការរស់នៅប្រជាពលរដ្ឋឡើយ។ លោកថា ករណីដីហុយនេះ គឺធ្វើឱ្យប៉ះពាល់ដល់សុខភាពពលរដ្ឋធ្ងន់ធ្ងរ ជាពិសេសកុមាររងគ្រោះលើបញ្ហាសុខភាពណាស់។

លោកថ្លែងថា៖«**រឿងដីហុយនេះ គឺវាប៉ះពាល់សុខភាពកុមារណាស់។ អាជ្ញាធរមូលដ្ឋានត្រូវតែពិនិត្យមើលលើរឿងហ្នឹងដោយយកចិត្តទុកដាក់ផង ព្រោះការរស់នៅពលរដ្ឋសំខាន់ណាស់។ បញ្ហាស្រោចទឹកនេះគឺខាងក្រុមហ៊ុនត្រូវតែចេញមុខដោះស្រាយនឹងប្រជាពលរដ្ឋ បើមិនអញ្ចឹងទេបញ្ហានេះនៅតែបន្តដដែល**»។

ក្រុមហ៊ុនសាងសង់ព្រលានយន្តហោះកម្ពុជា (CAIC) គឺជាក្រុមហ៊ុនចម្រុះបង្កើតឡើងរួមគ្នាដោយ ក្រុមហ៊ុន OCIC និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកម្ពុជា ក្នុងឆ្នាំ២០១៨ ក្រោមការណែនាំរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីធ្វើការងារសាងសង់ព្រលានយន្តភ្នំពេញថ្មី ដែលស្ថិតនៅចម្ងាយ២០គីឡូម៉ែត្រពីរាជធានីភ្នំពេញ ដែលមានផ្ទៃដីសរុប២៦០០ហិកតា។

គម្រោងសាងសង់នេះមាន៣ដំណាក់កាល គឺដំណាក់កាលទី១នេះត្រូវបានក្រុមហ៊ុន អះអាងថា គ្រោងនឹងចំណាយថវិកា១៥០០លានដុល្លារអាមេរិក ដែលមិនទាន់គិតបញ្ចូលតម្លៃដីនៅឡើយនោះទេ ដែលអាចនឹងទទួលបានភ្ញៀវទេសចរ ១៣លាននាក់ក្នុង១ឆ្នាំ ហើយដំណាក់កាលទី២ នឹងបញ្ចប់នៅឆ្នាំ២០៣០ អាចទទួលភ្ញៀវទេសចរ៣០លាននាក់ក្នុង១ឆ្នាំ និងដំណាក់កាលទី៣ នឹងបញ្ចប់នៅឆ្នាំ២០៥០ អាចទទួលភ្ញៀវទេសចរ ៥០លាននាក់ក្នុង១ឆ្នាំ៕